# ទីក្រុងតាកូម៉ាដំនើរការបណ្តឹងTitle VI

មនុស្សណាក៏ដោយដែលជឿជាក់ថាខ្លួនឯងត្រូវបានគេប្រកាន់រើសអើងដោយសារពូជសាសន៍ ព៍ណសំបុរ ឬជាតិកំនើតដើមដោយទីក្រុងតាកូម៉ាអាចដាក់ពាក្យបណ្តឹង Title VI ដោយធ្វើការទំនាក់ទំនងមកកាន់

ភ្នាក់ងារ៕ អ្នកដាក់ពាក្យប្តឹងត្រូវបំពេញនិងផ្ញើរទំរង់ Title VI Complaint ដែលមានភ្ជាប់ខាងក្រោម

ដើម្បីសំរួលការសើបអង្កេតអោយបានឆាប់ជាង៕ ទីក្រុងតាកូម៉ានឹងធ្វើការស៊ើបអង្កេតរាល់បណ្តឹង

ទាំងអស់ដែលទទួលបានក្នុងរយៈពេល១៨០ថ្ងៃនៃឧបត្តិហេតុចោទប្រកាន់៕

ពេលទីក្រុងតាកូម៉ាទទួលបានពាក្យបណ្តឹងហើយ ពាក្យបណ្តឹងនោះនឹងត្រូវបានពិនិត្យពិច័យដើម្បី

កំណត់ថាតើបណ្តឹងនោះអនុលោមទៅតាមបណ្តឹងTitle VI ហើយ/ឬថាតើមានព៍តមានគ្រប់គ្រាន់សំរាប់

ការស៊ើបអង្កេតមួយឬទេ៕ អ្នកប្តឹងនឹងទទួលបានលិខិតជូនដំនឹងមួយប្រាប់ថាបណ្តឹងនោះ

គ្របដណ្តប់ក្រោមTitle VIឬក៏អត់៕

ទីក្រុងតាកូម៉ាជាទូទៅនឹងបំពេញការស៊ើបអង្កេតមួយក្នុងរយៈពេល៩០ថ្ងៃគិតចាប់តាំងពីទទួលបានទំរង់ហ្វមបណ្តឹងដែលបានបំពេញរួច៕ ប្រសិនបើត្រូវការព៍តមានបន្ថែមដើម្បីដោះស្រាយហេតុការណ៍ នោះទីក្រុងតាកូម៉ានឹងទំនាក់ទំនងទៅដើមបណ្តឹង៕ប្រសិនបើទីក្រុងតាកូម៉ាមិនបានបញ្ជាក់ពីរយៈពេលយូរប៉ុណ្ណាទេ នោះអ្នកដើមបណ្តឹងនឹងមានរយៈពេល១០ថ្ងៃពីកាលបរិច្ឆេទនៅលើសំបុត្រដើម្បីផ្ញើរពត៍មាន

ដែលបានស្នើសុំនោះទៅអោយអ្នកស៊ើបអង្កេតទទូលបន្ទុកបណ្តឹងរបស់ទីក្រុងតាកូម៉ា៕

ប្រសិនបើអ្នកស៊ើបអង្កេតរបស់ទីក្រុងតាកូម៉ាមិនត្រូវបានទាក់ទងដោយដើមបណ្តឹងឬមិនទទួលបាន

មកវិញនូវពត៍មានបន្ថែមក្នុងពេលវេលាត្រូវការណាមួយនោះទេទីក្រុងតាកូម៉ានឹងបិទសំណុំក្តីនេះតាម

បែបបទរដ្ឋបាល៕សំណុំរឿងក្តីមួយអាចត្រូវបិទតាមបែបបទរដ្ឋបាលផងដែរប្រសិនបើអ្នកដើមបណ្តឹង ប្រាថ្នាមិនចង់បន្តរឿងក្តីនេះទៅមុខទៀត៕

ទីក្រុងតាកូម៉ានឹងស៊ើបអង្កេតពាក្យបណ្តឹង Title VI ដែលខ្លួនមានព៍តមានគ្រប់គ្រាន់៕ ក្រោយកាស៊ើបអង្កេតរបានបញ្ចប់ទៅ ដើមបណ្តឹងនឹងទទួលបានលិខិតមួយក្នុងចំណោមលិខិតពីរៈ លិខិតបិទមួយឬក៏លិខិតរកឃើញមួយ៕ លិខិតបិទមួយសង្ខេបពីការចោទប្រកាន់នានា ថែងថាការ

រំលោភTitle VI មួយមិនអាចបង្កើតឡើងបាន រួចជំរាបប្រាប់ដើមបណ្តឹងថាសំនុំរឿងនេះនឹងត្រូវបិទ៕ ចំនែកឯលិខិតរកឃើញមួយសង្ខេបពីការចោទប្រកាន់នានាហើយពន្យល់ថាតើប្រភេទសកម្មភាពកែតំរូវអ្វីត្រូវបានផ្តល់យោបល់ឬក៏ចាត់វិធានការណ៍បន្ត៕

ដើមបណ្តឹងម្នាក់អាចប្តឹងឧទ្ធរណ៍នូវសេចក្តីសំរេចចិត្តដោយផ្ញើរសំនើរជាលាយលក្ខណ៍អក្សរមួយទៅកាន់ អនុប្រធាននាយកប្រតិបត្តទីក្រុងតាកូម៉ាក្នុងរយៈពេល(១៥)ថ្ងៃធ្វើការងារគិតពីកាលបរិច្ឆេទលើលិខិត

បិទឬលិខិតរកឃើញ៕សំនើរប្តឹងឧទ្ធរណ៍នេះត្រូវបញ្ជាក់អំពីគោលការណ៍សំខាន់ដែលជាមូលដ្ឋាននៃការ

ប្តឹងនេះ៕អនុប្រធាននាយកប្រតិបត្តិនឹងជំរាបទៅដើមបណ្តឹងក្នុងរយៈពេល១០ថ្ងៃអំពីសេចក្តីសំរេចចិត្ត ថាតើត្រូវគេទទួលយកឬក៏បដិសេធសំនើរសុំប្តឹងឧទ្ធរណ៍៕ ក្នុងករណីប្តឹងឧទ្ធរណ៍ត្រូវបានផ្តល់ជូន នោះអនុប្រធាននាយកប្រតិបត្តិនឹងចេញលិខិតសំរេចចិត្តមួយជូនទៅដើមបណ្តឹងក្រោយពេលការ

ពិនិត្យលើបណ្តឹងឧទ្ធរណ៍នោះត្រូវបានបញ្ចប់៕

មនុស្សម្នាក់អាចដាក់ពាក្យបណ្តឹងដោយផ្ទាល់ជាមួយក្រសួងដឹកជញ្ជូនសហរដ្ឋអាមេរិកដោយទំនាក់ទំនង មកក្រសួង: ក្រសួងដឹកជញ្ជូនការិយាល័យរដ្ឋបាលនៃសិទ្ធិប្រជាពលរដ្ឋបណ្តោះអាសន្នសហព័ន្ធ ក្រុមទទួលពាក្យបណ្តឹង អាគារខាងកើត ជាន់ទី៥ TCR, ១២០០ New Jersey Avenue, SE, Washington, DC២០៥៩០ ឬទូរស័ព្ទមកកាន់ ១-៨៨៨-៤៦៦-៤៥១១៕

ព័តមានទំនាក់ទំនងមកទីក្រុងតាកូម៉ា
សំរាប់ពត៍មានបន្ថែមស្តីអំពីគោលនយោបាយ និងនិតិវិធីសំរាប់ដាក់ពាក្យបណ្តឹងTitle VI របស់ទីក្រុងតាកូម៉ា  ទំនាក់ទំនង ២៥៣-៥៩១-៥០០០, TTY Relay ៧១១ឬអុិមើល cityoftacoma.org/Tacomafirst ឬផ្ញើរលិខិតមកកាន់ Customer Support Centre (មជ្ឈមណ្ឌលគាំទ្រអតិថិជន) ៧៤៧ Market Street, បន្ទប់ Room  ២៤៣, Tacoma, WA ៩៨៤០២.